# ការស្វែងយល់ពីតួនាទី មូលធនសង្គម នៅពេលមាន ទឹកជំនន់ និងគ្រោះរាំងស្ងួត

*លោកស្រី អាង សូផា លោក អឿ អ៊ីល និង John McAndrew សិក្សាពីតួនាទីមូលធនសង្គម ក្នុងការជួយអ្នកភូមិប្រឈមមុខនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ ក្នុងតំបន់អេកូឡូស៊ីពីរនៅខេត្តកំពង់ធំ ។**

## សេចក្តីផ្តើម

ប្រទេសកម្ពុជា បានឈានចូលសតវត្សរ៍ទី២១ នេះ ដោយសង្ឃឹមថានឹងបានមកដល់សម័យមានសន្តិភាព និងតម្លាភាពហើយ ប៉ុន្តែបែរជារងគ្រោះដោយសារទឹកជំនន់ និងការរាំងស្ងួតអស់ ៥ឆ្នាំជាប់ៗគ្នាទៅវិញ ។ ទឹកជំនន់នៅឆ្នាំ២០០០/០១ ដែលជាគ្រោះធម្មជាតិធ្ងន់ធ្ងរជាងគេក្នុងរយៈ ៧០ឆ្នាំចុងក្រោយ បានប៉ះពាល់ដល់ប្រជាពលរដ្ឋ ៣,៤លាននាក់ ហើយទឹកជំនន់ឆ្នាំ២០០០/០២ បានប៉ះពាល់ដល់ ប្រជាពលរដ្ឋ ២,១លាននាក់ នៅក្នុងតំបន់ដែលកំពុងរើខ្លួននៅឡើយពីការលិចលង់កាលពីឆ្នាំមុន ។ សំរាប់ការរាំងស្ងួតនៅឆ្នាំ២០០២/០៣ រដ្ឋាភិបាលបានរាយការណ៍ថា ជាគ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរបំផុតក្នុងរយៈ ២០ឆ្នាំចុងក្រោយ ហើយបានប៉ះពាល់ដល់ប្រជាជនជាង ២លាននាក់ ។ ការរាំងស្ងួតនៅឆ្នាំ២០០៣/០៤ បានធ្វើឱ្យបឹងនៅតាមកន្លែងទំនាបទាបៗបំផុតនៃវាលលិចទឹក ត្រូវរីងស្ងួតអស់ ។ នៅឆ្នាំ២០០៤/០៥ គ្រោះរាំងស្ងួតបានប៉ះពាល់ដល់ប្រជាជន ២លាននាក់ និងបង្កកង្វះខាតស្បៀងអាហារនៅគ្រប់ទិសទី (Chan 2001; Nhim Vanda 2002; Asian Disaster Reduction Center 2003; Helmers and Jegillos 2004; Mao 2005) ។ អត្ថបទនេះ ពិនិត្យពីផលប៉ះពាល់នៃទឹកជំនន់ និងការរាំងស្ងួត ទៅលើទិន្នផលស្រូវ និងបែបបទនៃការកចិញ្ចឹមជីវិតនៅក្នុងឆ្នាំទាំងនោះ នៅក្នុងឃុំចំនួនពីរដែលមានប្រព័ន្ធអេកូឡូស៊ីខុសគ្នា នៅខេត្តកំពង់ធំ និងស្រាវជ្រាវពីតួនាទីនៃមូលធនសង្គម ដើម្បីជួយប្រជាជនរងគ្រោះអោយប្រឈមមុខដោះស្រាយតំរូវការដ៏ចាំបាច់នានា ។

## វិធីសាស្ត្រស្រាវជ្រាវ

ការចុះស្រាវជ្រាវដល់កន្លែងបានធ្វើឡើងនៅខែមិថុនា ឆ្នាំ២០០៥ នៅ ២តំបន់អេកូឡូស៊ី ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ គេបានជ្រើសយក ៣ភូមិ ក្នុងឃុំសានគរ ធ្វើជាតំបន់អេកូឡូស៊ីមួយនៃការសិក្សា ។ ភូមិទាំង៣ ស្ថិតក្នុងតំបន់វាលទំនាបលិចទឹកជិតបឹងទន្លេសាប តាមខាងលិចដងផ្លូវជាតិលេខ៦ នៅជិតផ្សារឃុំសានគរ ។ ភូមិចំនួន ២ ក្នុងឃុំដំរីស្លាប់ បានជ្រើសយកធ្វើជាតំបន់អេកូឡូស៊ីមួយទៀត ។ ភូមិទាំង២ ស្ថិតក្នុងតំបន់ដីខ្ពស់ ខាងក្រៅវាលទំនាបលិចទឹក ជិតបឹងទន្លេសាប តាមខាងកើតដងផ្លូវជាតិលេខ៦ ចំងាយប្រហែល ៨ ទៅ ១២គ.ម ពីផ្សារឃុំសានគរ ។ គិតជាសរុប បានធ្វើអង្កេតលើ ១៥៥គ្រួសារ ក្នុង ៣ភូមិ នៅឃុំសានគរ គឺ ភូមិអំពិល ភូមិជ័យ និងភូមិស្លែងខ្ពស់ និង ១០០គ្រួសារទៀត ក្នុង ២ភូមិ នៅឃុំដំរីស្លាប់ គឺ ភូមិសង្គម និងភូមិវល្លិយាវ ។ ជាបន្ថែមលើអង្កេតនេះ គេបានធ្វើសំភាសន៍ជាលក្ខណៈក្រុមមុខសញ្ញាជាមួយ អាជ្ញាធរមូលដ្ឋាន អ្នកដឹកនាំក្នុងមូលដ្ឋាន នារីអ្នកភូមិ និងបុរសអ្នកភូមិ ។ ម្យ៉ាងទៀត បានជ្រើសរើសគ្រួសារមួយចំនួន មកធ្វើសំភាសន៍ជាលក្ខណៈអ្នកផ្តល់ព័ត៌មានគន្លឹះ[1] ។

## គោលគំនិតនៃមូលធនសង្គម

គោលគំនិតនៃមូលធនសង្គម អាចមានប្រយោជន៍ច្រើនដល់ការវិភាគពីបែបបទដែលប្រជាជនប្រឈមមុខនឹងគ្រោះធម្មជាតិដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត ។ Robert Putnam ដែលជាអ្នកជួយផ្សព្វផ្សាយពីគោលគំនិតនេះ បានអោយនិយមន័យមូលធនសង្គម ថាជា "លក្ខណៈនានានៃការរៀបចំសង្គមដូចជា ទំនុកចិត្ត របៀបរបប និង បណ្តាញផ្សេងៗ ដែលអាចបង្កើនប្រសិទ្ធភាពសង្គម ដោយជួយសំរួលដល់ សកម្មភាពមានការសំរបសំរួលល្អ" (១៩៩៣) ។ Putnam យល់ឃើញថា ប្រភពចំបងនៃទំនុកចិត្តក្នុងសង្គម គឺរបបបដិការ និងបណ្តាញនៃការចូលពាក់ព័ន្ធ ដែលអាចវាស់វែងបានតាមរយៈការចូលរួមរបស់ប្រជាជននៅក្នុងសមាគមនានា ។ ដង់ស៊ីតេនៃសមាគមបែបនេះ ដែលអាចវាស់វែងជាសំខាន់តាមរយៈអង្កេតបែបបរិមាណ វាបង្ហាញថាសង្គមណាមួយនោះមានមូលធនសង្គមធំទូលាយប៉ុណ្ណា ។

ការរិះគន់នាពេលថ្មីៗដល់វិធីសាស្ត្ររបស់ Putnam បានប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យច្រើន ហើយផ្តោតលើលទ្ធភាពរបស់ប្រជាជនដើម្បីប្រើប្រាស់ធនធានជាមូលធនសង្គម និងបរិបទដែលហ៊ុំព័ទ្ធបណ្តាញសង្គមនោះ (Grix 2001) ។ កត្តាផ្សេងៗដូចជា ការអប់រំ វត្តមានការងារ និង វណ្ណៈសង្គម វាសំខាន់បំផុតដើម្បីស្វែងយល់ពី លទ្ធភាពរបស់អ្នកណាម្នាក់ក្នុងការប្រើប្រាស់មូលធនសង្គម ដោយទទួលស្គាល់ថា ការចូលរួមនៅក្នុងសមាគម និងបណ្តាញផ្សេងៗ វាពឹងផ្អែកជាសំខាន់ទៅលើធនធាន និងឋានៈសង្គមរបស់អ្នកនោះ ។ ដូចគ្នាដែរ បរិបទសង្គមជាក់លាក់ណាមួយ វាកំនត់ពីទំរង់នៃមូលធនសង្គមដែលត្រូវផុសឡើង ហើយនិងទំនោរនៃលទ្ធភាពទទួលបានការប្រើប្រាស់មូលធនទាំងនោះ ។

លទ្ធភាពរបស់បុគ្គលណាមួយដើម្បីបានប្រើប្រាស់មូលធនសង្គម វាអាស្រ័យជាសំខាន់ទៅលើ ការរាប់បញ្ចូល រឺការផាត់ចេញបុគ្គលនោះនៅក្នុងសង្គម ។ ដោយមូលហេតុនេះ បណ្តាញសង្គមអាចបែងចែកជា ៣ប្រភេទសំខាន់ៗគឺ : ចំណងផ្សារភ្ជាប់ (bond) ស្ពានចំលង (bridge) និងចំណងទាក់ទង (link) (Woolcock 1998; Narayan 1999) ។ មូលធនសង្គមដែលជាចំណងផ្សារភ្ជាប់ រួមមានចំណងដ៏រឹងមាំតាមខ្សែផ្តេកជាមួយ សមាជិកគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង ដែលតែងជួយកាត់បន្ថយភាពងាយទទួលរងគ្រោះ និងផ្តល់នូវបណ្តាញសុវត្ថិភាពសង្គម ។ មូលធនសង្គមជាស្ពានចំលង រួមមានចំណងក៏រិតខ្សោយតាមខ្សែផ្តេក ដែលតភ្ជាប់បុគ្គលនៅក្នុងក្រុម និងបណ្តាញផ្សេងៗ ទៅនឹងជនឯទៀត ដែលមានស្ថានភាពសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ។ ការតស្ពានចំលងជាមួយ មនុស្សនៅខាងក្នុង និងខាងក្រៅសហគមន៍ វាផ្តល់ឱកាសល្អៗសំរាប់ការកែលំអជីវភាព នឹងលទ្ធភាពធ្វើបំលាស់ទី ។ មូលធនសង្គមចំណងទាក់ទង គឺជាចំណងតាមខ្សែបញ្ឈរដែលតភ្ជាប់បុគ្គលទៅនឹង

* អាង សូផា ទទួលសញ្ញាប័ត្រអនុបណ្ឌិតពីវិទ្យាស្ថាន AIT (Asian Institute of Technology) និងធ្លាប់ធ្វើជាអ្នកសំរបសំរួលគំរោងវិភាគពីបញ្ហាអភិវឌ្ឍន៍ (ADI) របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) នៅពេលកំពុងធ្វើការស្រាវជ្រាវ ។ អឿ អ៊ីល ទទួលសញ្ញាប័ត្រអនុបណ្ឌិតពីសាកលវិទ្យាល័យន័រតុន និងបានចូលជាសមាជិកក្រុម ADI តាំងពីឆ្នាំ១៩៩៩ ។ John McAndrew ទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតពីសាកលវិទ្យាល័យ Amsterdam និងបានធ្វើជាទីប្រឹក្សានៃគំរោង ADI តាំងពីឆ្នាំ២០០៣ ។

*តារាង ១. គ្រួសារធ្លាប់រងគ្រោះដោយទឹកជំនន់ធ្ងន់ធ្ងរ រឺធម្មតា ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥, នៅភូមិ អំពិល, ជ័យ និងស្លែងខ្ពស់ ក្នុងឃុំសានគរ ហើយនិងភូមិសង្គម និងវល្លិយាវ ក្នុងឃុំដីវីស្លាប់ ( មិថុនា ២០០៥)*

| ឆ្នាំ | ទឹកជំនន់ធ្ងន់ធ្ងរ | | ទឹកជំនន់ធម្មតា | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| 2004/05 | 3 | 2 | 102 | 66 |
| 2003/04 | 9 | 6 | 105 | 68 |
| 2002/03 | 58 | 37 | 70 | 45 |
| 2001/02 | 134 | 86 | 18 | 12 |
| 2000/01 | 147 | 95 | 5 | 3 |
| N=155 | | | | |

អ្នកមានអំនាច/ឥទ្ធិពល ដូចជា ធនាគារ ស្ថាប័នរដ្ឋ និងមន្ត្រីជាប់ឆ្នោត ។ ចំណងទាក់ទងជាមួយបុគ្គល និងស្ថាប័នដ៏មានអំនាច ជួយឱ្យបុគ្គលអាចប្រើប្រាស់ធនធានបានកាន់តែសក្តិសិទ្ធិ ដើម្បីទាញយកផលប្រយោជន៍ក្នុងរយៈពេលវែង ។ មនុស្សដែលមានបណ្តាញរឹងមាំនៅក្នុងប្រភេទណាមួយ រឺគ្របដណ្តប់លើប្រភេទទាំងបី តែងតែមានសមត្ថភាពល្អប្រសើរ ដើម្បីប្រឈមមុខនឹងគ្រោះមហន្តរាយ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម ។

## បទពិសោធន៍នៃទឹកជំនន់[២]

គ្រួសារដែលត្រូវបានចុះអង្កេតនៅឃុំសានគរ ក្នុង ៣ភូមិ គឺ អំពិល ជ័យ និងស្លែងខ្ពស់ ធ្លាប់រងគ្រោះដោយសារទឹកជំនន់ដ៏ធ្ងន់ធ្ងរចំនួន ៥ឆ្នាំ ពីឆ្នាំ ២០០០/០១ ដល់ ២០០៤/០៥ ( តារាង១) ។ ពួកគេភាគច្រើនបានរងគ្រោះដោយទឹកជំនន់កាលពីឆ្នាំ ២០០០/០១ និង ២០០១/០២ ហើយជាង ១/៣ បានរងគ្រោះដោយទឹកជំនន់នៅឆ្នាំ២០០២/០៣ ។ គ្រួសារឆ្លើយសំភាសន៍ជាង ១/៤ រាយការណ៍ថា ពួកគេត្រូវជម្លៀសចេញពីលំនៅដ្ឋានដោយសារតែទឹកជំនន់ ។ ពួកគេ ៩០% មានសមាជិក គ្រួសារធ្លាក់ខ្លួនឈឺ ដែលភាគច្រើនជាជំងឺរាគរូស និងចុកពោះ ។ ទឹកជំនន់ធ្ងន់ធ្ងរច្រើនឆ្នាំជាប់ៗគ្នា ធ្វើឱ្យខូចខាតយ៉ាងខ្លាំងដល់ចំណូលពីកសិកម្ម និងរារាំងអ្នកភូមិមិនឱ្យរើខ្លួនបានឆាប់ឡើងវិញ ។ ជំនួយពីបណ្តាស្ថាប័នខាងក្រៅ មានប្រយោជន៍ណាស់ ប៉ុន្តែមិនគ្រប់គ្រាន់ ដូច្នេះគ្រួសារនានាត្រូវតែពឹងផ្អែកជាសំខាន់លើធនធានផ្ទាល់ខ្លួនដើម្បីស្តារជីវភាព ។ ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង និងមិត្តភក្តិ ផុសផុលខ្លាំងណាស់នៅពេលទឹកជំនន់មកដល់ភ្លាម ប៉ុន្តែត្រូវថយចុះដោយសារភាពក្រីក្ររបស់អ្នកភូមិ ។ គួរកត់សំគាល់ថា គ្រួសារអ្នកឆ្លើយសំភាសន៍ក្នុង ២ភូមិ នៅឃុំដីវីស្លាប់ ដែលស្ថិតនៅខាងក្រៅតំបន់ទំនាបលិចទឹកបឹងទន្លេសាប មិនបានរងគ្រោះដោយសារទឹកជំនន់ទេក្នុងប៉ុន្មានឆ្នាំនោះ ។

## បទពិសោធន៍នៃគ្រោះរាំងស្ងួត

គ្រួសារដែលយើងបានចុះអង្កេតក្នុងឃុំទាំង២ គឺធ្លាប់រងគ្រោះដោយការរាំងស្ងួតធ្ងន់ធ្ងរ ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ (តារាង២) ។ លើកលែងតែការដាំដុះក្នុងឆ្នាំ២០០២/០៣ ភូមិអង្កេតទាំង៣ នៅឃុំសានគរ បានជួបការរាំងស្ងួតប្រចាំឆ្នាំធ្ងន់ធ្ងរជាង ២ភូមិទៀត នៅឃុំដីវីស្លាប់ ក្នុងរយៈពេល ៥ឆ្នាំនៃការសិក្សា ។ ចំណុចនេះគួរកត់សំគាល់ណាស់ ពីព្រោះក្នុងអំឡុងពេលដូចគ្នា ភូមិនានានៅឃុំសានគរ ក៏បានជួបនឹងទឹកជំនន់ធ្ងន់ធ្ងរដែរ ។ ក្នុងបញ្ហាសុខភាព គេឃើញមានដូចមុននូវ ជំងឺរាគរូស ចុកពោះ និងការខាតបង់ចំណូលដោយសារការខូចសំណាបនិងផលស្រូវ ប៉ុន្តែនៅឃុំដីវីស្លាប់ វាធ្ងន់ធ្ងរជាងបន្តិច ។ រឿងនេះ ក៏អាចមកពីនៅឃុំដីវីស្លាប់ មានចំនួនភាគរយច្រើនជាងនៃ គ្រួសារដែលបានទទួលជំនួយក្នុងពេលមានការរាំងស្ងួតខ្លាំង ។ តាមធម្មតានៅពេលមានការរាំងស្ងួតធ្ងន់ធ្ងរ គេមិនសូវមើលឃើញថាមានតំរូវការច្រើន ដូចនៅពេលមានទឹកជំនន់ធ្ងន់ធ្ងរទេ ។

*តារាង ២. គ្រួសារធ្លាប់រងគ្រោះដោយការរាំងស្ងួតធ្ងន់ធ្ងរ រឺ ធម្មតា នៅឆ្នាំ ២០០០/០១ ដល់ ២០០៤/០៥ ( មិថុនា ២០០៥)*

| ឆ្នាំ | ភូមិអំពិល ជ័យ និងស្លែងខ្ពស់ ក្នុងឃុំសានគរ | | | | ភូមិសង្គម និងវល្លិយាវ ក្នុងឃុំដីវីស្លាប់ | | | |
|---|---|---|---|---|---|---|---|---|
| | រាំងស្ងួតធ្ងន់ធ្ងរ | | រាំងស្ងួតធម្មតា | | រាំងស្ងួតធ្ងន់ធ្ងរ | | រាំងស្ងួតធម្មតា | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| 2004/05 | 67 | 43 | 66 | 43 | 7 | 7 | 69 | 69 |
| 2003/04 | 92 | 59 | 55 | 35 | 41 | 41 | 53 | 53 |
| 2002/03 | 67 | 43 | 73 | 47 | 76 | 76 | 21 | 21 |
| 2001/02 | 42 | 27 | 66 | 43 | 19 | 19 | 72 | 72 |
| 2000/01 | 34 | 22 | 65 | 42 | 9 | 9 | 67 | 67 |
| | N= 155 | | | | N=100 | | | |

*តារាង ៣. ផលស្រូវមធ្យមតាមគ្រួសារ ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ នៅភូមិអំពិល ជ័យ និងស្លែងខ្ពស់ ក្នុងឃុំសានគរ ( មិថុនា ២០០៥)*

| ឆ្នាំ | ផលស្រូវវស្សាមធ្យម (គ.ក្រ) | ផលស្រូវប្រាំងមធ្យម (គ.ក្រ) | ផលស្រូវសរុបមធ្យម (គ.ក្រ) |
|---|---|---|---|
| 2004/05* | 696 | 166 | 693 |
| 2003/04** | 410 | 180 | 406 |
| 2002/03*** | 328 | 0 | 325 |
| 2001/02**** | 207 | 480 | 210 |
| 2000/01***** | 120 | 480 | 124 |

*N = 125 សំរាប់រដូវវស្សា, 6 សំរាប់រដូវប្រាំង, 127 សំរាប់សរុប
**N = 102 សំរាប់រដូវវស្សា, 2 សំរាប់រដូវប្រាំង, 104 សំរាប់សរុប
***N = 88 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 89 សំរាប់សរុប
****N = 79 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 80 សំរាប់សរុប
*****N = 80 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 81 សំរាប់សរុប

## ទិន្នផលស្រូវពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥

ភូមិសិក្សាទាំង៣ នៅឃុំសានគរ និងភូមិទាំង២ នៅឃុំដីរីស្លាប់ មានការពឹងផ្អែកយ៉ាងខ្លាំងលើផលស្រូវវស្សា ។ ដោយសារមានទឹកជំនន់ និងការរាំងស្ងួតធ្ងន់ធ្ងរ ភូមិនានាក្នុងឃុំទាំងពីរ មានផលស្រូវទាបខ្លាំងណាស់ក្នុងបណ្ដាឆ្នាំមានគ្រោះធម្មជាតិដែលបានសិក្សា (តារាង ៣ និង ៤) ។ ដោយសារស្ថានភាពដី ផលស្រូវនៅភូមិនានាក្នុងឃុំសានគរ បានចុះទាបបំផុតនៅពេលមានទឹកជំនន់ប៉ះពាល់ខ្លាំងបំផុត រីឯផលស្រូវនៅភូមិនានាក្នុងឃុំដីរីស្លាប់ បានចុះទាបបំផុតនៅពេលមានការរាំងស្ងួតប៉ះពាល់ខ្លាំងបំផុត ។ ទោះបីនៅក្នុងឆ្នាំដែលបានផលល្អបំផុត និងទោះបីស្ថិតក្នុងតំបន់អេកូឡូស៊ីពីរខុសគ្នាក្ដី ក៏ទិន្នផលក្នុងឃុំទាំង២ ទាបជាង ០,៥តោន/ហិកតា (ក្នុង ៥ឆ្នាំសិក្សា មាន ៣ឆ្នាំដែលឃុំដីរីស្លាប់ទទួលបានលើសពី ០,៥តោន/ហិកតា រីឯនៅឃុំសានគរមាន ១ឆ្នាំប៉ុណ្ណោះ) ។ កង្វះខាតស្រូវដែលឃើញមានជាធម្មតាទៅហើយនៅតាមឆ្នាំដូចធម្មតា វាក៏កើនថែមទៀតក្នុងអំឡុងពេលមានគ្រោះធម្មជាតិ ហើយវាបានកាត់បន្ថយការហូបចុករបស់គ្រួសារមួយភាគធំ ។

ការលក់ រឺបញ្ចាំដីស្រែ ច្រើនតែជាលទ្ធផលនៃទឹកជំនន់ និងការរាំងស្ងួតធ្ងន់ធ្ងរ ។ ការបាត់បង់ដីស្រែធ្វើឱ្យគ្រួសារកសិករដែលរកបានតែមួយរស់ៗ ពិបាករើខ្លួនឱ្យបានទាំងស្រុងពីផលអាក្រក់ផ្សេងៗនៃគ្រោះធម្មជាតិ ហើយក៏ត្រូវបន្ថយការធ្វើស្រែ ធ្វើជាសកម្មភាពរកចិញ្ចឹមជីវិតចំបងរបស់ខ្លួនទៀត ។ គ្រួសារដែលពុំមានដីគ្រប់គ្រាន់សំរាប់ធ្វើស្រែ និងដាក់ធានាខ្ចីប្រាក់ច្រើនតែត្រូវដាច់ឆ្ងាយពីគេថែមទៀត ដោយសារគ្រោះទឹកជំនន់ និងការរាំងស្ងួត ។ ការរានព្រៃយកដីធ្វើស្រែ គឺជាដំណោះស្រាយសំរាប់អ្នកភូមិជាច្រើនក្នុងឃុំទាំងពីរ ដើម្បីពង្រីកដីកាន់កាប់ ថ្វីបើវិធីនេះបានធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិដែលមានសារៈសំខាន់សំរាប់ការគ្រប់គ្រងទឹក ។

## ការផ្លាស់ប្ដូរជីវភាព

គ្រោះរាំងស្ងួតនិងទឹកជំនន់ដ៏ធ្ងន់ធ្ងរ ដែលកើតមានឡើងនៅតំបន់សិក្សាពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ បាននាំអោយមានដំណើរផ្លាស់ប្ដូរដ៏ធំទូលាយក្នុងសង្គមនៅក្នុងតំបន់បឹងទន្លេសាប និងតំបន់ឯទៀតនៅជនបទកម្ពុជា ។ ផលស្រូវក្នុងរយៈ ៥ឆ្នាំនៃគ្រោះធម្មជាតិបន្តបន្ទាប់គ្នា បានធ្លាក់ចុះទាបបំផុត ហើយបង្ខំអោយគ្រួសារជាច្រើនក្នុងភូមិទាំង ៥ ត្រូវពឹងផ្អែកទៅលើរបរចិញ្ចឹមជីវិតក្រៅពីធ្វើស្រែវស្សា ដូចជា ការនេសាទ ការប្រមូលធនធានព្រៃឈើ និងចំណាកស្រុកទៅធ្វើការងារស៊ីប្រាក់ឈ្នួល ។ ដើម្បីប៉ះប៉ូវការខូចខាតផលស្រូវ គ្រួសារនានានៅឃុំសានគរ ក្នុងតំបន់វាលលិចទឹកបឹងទន្លេសាប បានទាញយកផលពីធនធានត្រីនៅក្នុងបឹង រីឯគ្រួសារនៅឃុំដីរីស្លាប់ បានកាប់ឈើ និងធ្វើឡធ្យូង ។ ការផ្លាស់ប្ដូរភ្លាមៗមកប្រើប្រាស់ប្រភពចំណូលពីធនធានទាំងនេះ បានរួមចំណែកធ្វើឱ្យថយចុះធនធានធម្មជាតិ ។

ក្នុងពេលជាមួយគ្នា គ្រួសារជាច្រើននៅឃុំទាំង២ បានពឹងផ្អែកកាន់តែខ្លាំងទៅលើចំណាកស្រុក ទៅធ្វើពលកម្មស៊ីប្រាក់ឈ្នួលដើម្បីទ្រទ្រង់ជីវភាព ។

*តារាង ៤. ផលស្រូវមធ្យមតាមគ្រួសារ ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ នៅភូមិសង្គម និងវល្លិយាវ ក្នុងឃុំដីរីស្លាប់ ( មិថុនា ២០០៥)*

| ឆ្នាំ | ផលស្រូវវស្សាមធ្យម (គ.ក្រ) | ផលស្រូវប្រាំងមធ្យម (គ.ក្រ) | ផលស្រូវសរុបមធ្យម (គ.ក្រ) |
|---|---|---|---|
| 2004/5* | 553 | 432 | 595 |
| 2003/4** | 353 | 216 | 363 |
| 2002/3*** | 365 | 97 | 367 |
| 2001/2**** | 582 | --- | 582 |
| 2000/1***** | 691 | --- | 691 |

*N = 91 សំរាប់រដូវវស្សា, 9 សំរាប់រដូវប្រាំង, 91 សំរាប់សរុប
**N = 89 សំរាប់រដូវវស្សា, 4 សំរាប់រដូវប្រាំង, 89 សំរាប់សរុប
***N = 82 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 82 សំរាប់សរុប
****N = 77 សំរាប់រដូវវស្សា, --- សំរាប់រដូវប្រាំង, 77 សំរាប់សរុប
*****N = 72 សំរាប់រដូវវស្សា, --- សំរាប់រដូវប្រាំង, 72 សំរាប់សរុប

ក្នុងរយៈ ៥ឆ្នាំក្រោមការសិក្សា ជិត ៦០% នៃសមាជិកគ្រួសារមកពីឃុំសានគរ និងប្រហែល ៥០% នៃគ្រួសារមកពីឃុំដីរស្លាប់ បានចាកចេញពីភូមិទៅរកចំណូល ជាពិសេសធ្វើជាអ្នកស៊ីឈ្នួលធ្វើស្រែចំការនៅថៃ និងធ្វើកម្មកររោងចក្រកាត់ដេរនៅភ្នំពេញ ។ ការងារចំណាកស្រុកដែលកាលពីមុនគ្រាន់តែផ្តល់ចំណូលបន្ថែមសំរាប់រយៈពេលខ្លី វាបានក្លាយជាយុទ្ធសាស្ត្ររកចិញ្ចឹមជីវិតចំបងគេសំរាប់គ្រួសារជាច្រើន ។

ដោយមិនអាចពឹងផ្អែកលើផលិតកម្មស្រូវ ហើយការងារក្រៅកសិដ្ឋាន ក៏មានតិច គ្រួសារជាច្រើន ត្រូវខ្ចីបុលក្នុងអត្រាការប្រាក់ខ្ពស់ហួសហេតុ ដើម្បីទ្រទ្រង់ជីវិតប្រចាំថ្ងៃ ។ គ្រួសារជាច្រើនក៏ត្រូវខ្ចីប្រាក់ច្រើនៗ ក្នុងអត្រាការប្រាក់ដ៏ខ្ពស់ ដើម្បីដោះស្រាយចំណាយព្យាបាលជំងឺ ។ គ្រួសារមួយចំនួនបានលក់ រឺបញ្ចាំដីស្រែ ដើម្បីបានប្រាក់ រឺសងបំណុលគេ ហើយក៏ធ្វើអោយថយចុះដល់សមត្ថភាពរបស់ខ្លួន ក្នុងការធ្វើស្រែជាសំខាន់ ដើម្បីទ្រទ្រង់ជីវភាព ។ តាមការក្រឡេកមើលទៅក្រោយវិញ គ្រោះធម្មជាតិដែលចាប់ផ្តើមដោយ ទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅឆ្នាំ ២០០០/០១ បានធ្វើគ្រួសារជាច្រើនប្រែប្រួលជីវភាព ។

## ការពឹងផ្អែកលើបណ្តាញមូលធនសង្គម

ក្នុងការប្រឈមនឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនេះ យើងបានធ្វើសំភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ និងធ្វើអង្កេត ដោយប្រឹងពិនិត្យមើលពីផលប្រយោជន៍នៃមូលធនសង្គម ។ នៅពេលមានទឹកជំនន់ មូលធនសង្គមដែលជាចំណងផ្សារភ្ជាប់ និងស្ពានចំលង បានស្តែងចេញយ៉ាងច្បាស់ ។ បណ្តាគ្រួសារនៅតាមភូមិក្នុងឃុំសានគរ បានជួយគ្នាទៅវិញទៅមក ដើម្បីជំលៀសសមាជិកគ្រួសារ មើលថែសត្វចិញ្ចឹម ដើរល្បាតការពារផ្ទះក្នុងភូមិ ដឹកកុមារទៅរៀន ចែកចាយទឹកស្អាត និងផ្តល់កំចីតូចៗជាស្រូវអង្ករឱ្យគ្នា ។ នៅពេលទឹកស្រកទៅវិញ គ្រួសារនានានៅឃុំសានគរ បានរួបរួមគ្នាជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ ដូចជា ប្រឡាយទឹក ទ្វារទឹក លូទឹក ផ្លូវ សាលារៀន ជាដើម ។ ជារឿយៗ មានស្ថាប័នខាងក្រៅបានមកជួយដល់ការប្រឹងប្រែងស្តារកសាងឡើងវិញទាំងនេះ ។

នៅពេលមានគ្រោះរាំងស្ងួត បណ្តាញមូលធនសង្គមជាចំណងផ្សារភ្ជាប់ និងជាស្ពានចំលង (ដែលតែងតូចជាងចំណងផ្សារភ្ជាប់) ក៏ស្តែងចេញយ៉ាងច្បាស់ដែរ ប៉ុន្តែមិនសូវលេចធ្លោដូចក្នុងសកម្មភាពដ៏មមាញឹក នៅពេលមានទឹកជំនន់ទេ ។ ក្នុងពេលមានគ្រោះរាំងស្ងួត សាច់ញាតិ និងអ្នកជិតខាងនៅតាមភូមិនានា តែងជួយគ្នាទៅវិញទៅមកដើម្បីបំពេញស្តុកពូជស្រូវឡើងវិញ ដោយផ្តល់ប្រាក់កំចីតូចៗ ជួយធានាកំចីពីអ្នកចងការប្រាក់ ជួយមើលថែអ្នកជំងឺ អនុញ្ញាតអោយប្រើប្រាស់អណ្តូងគ្រួសារ និង ជួយក្រុមអ្នកងាយរងគ្រោះ ។ ក្រោយពេលមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរ មូលធនសង្គមជាស្ពានចំលងតែងស្តែងចេញជាគ្រួសារនានាចូលធ្វើការរួមគ្នា នៅក្នុងគំរោងស្បៀងពលកម្មបំរើសហគមន៍ ដែលឧបត្ថម្ភដោយអង្គការពីខាងក្រៅ ។

ដូចគ្នាដែរ បណ្តាញមូលធនសង្គមជាស្ពានចំលង បានជួយគ្រួសារនានានៅឃុំទាំងពីរ ប្រឈមមុខដោះស្រាយតំរូវការដ៏ច្រើននៃការផ្លាស់ប្តូរសង្គមដែលកើតមានឡើងក្នុងដំណើរជីវិតរបស់ពួកគាត់ ។ ពលករចំណាកស្រុកចេញពីភូមិទាំងពីរ អាចរកបានការងារធ្វើនៅភ្នំពេញ រឺនៅថៃ ឆ្លងតាមខ្សែរយៈទំនាក់ទំនងជាមួយសាច់ញាតិ មិត្តភក្តិ អ្នកជិតខាង និងភ្នាក់ងារជ្រើសរើសពលករ ។ បុរស/នារីវ័យក្មេង មកពីបណ្តាភូមិក្នុងឃុំសានគរបានប្រើប្រាស់អ្នកស្គាល់គ្នាជាមួយម្ចាស់ឡូតិ៍នេសាទនៅបឹងទន្លេសាប ដើម្បីបានការងារជាកម្មករស៊ីឈ្នួល ។ គ្រួសារនៅឃុំទាំងពីរ ទទួលបានប្រាក់ពីអ្នកចងការប្រាក់នៅឯផ្សារឃុំសានគរ ដើម្បីបណ្តាក់ទុនឡើងវិញ ទៅលើផលិតកម្មស្រូវដែលងាយខូចខាតដោយគ្រោះធម្មជាតិ ទោះបីអត្រាការប្រាក់វាខ្ពស់ហួសហេតុ ហើយដំណាំស្រូវក៏ផ្សងព្រេងច្រើនក៏ដោយ ។ គ្រួសារនៅឃុំដីរស្លាប់ ក៏ពឹងផ្អែកដូចគ្នាលើអ្នកចងការប្រាក់ ដើម្បីដោះស្រាយតំរូវការបង់ប្រាក់ក្រៅផ្លូវការ ទៅអោយភ្នាក់ងាររដ្ឋ ដើម្បីបានការអនុញ្ញាតឱ្យចូលកាប់ឈើ និងដឹកឈើហ៊ុបចេញពីខេត្តព្រះវិហារ ។

តាមគំនិតលោក Robert Putnam អត្រាខ្ពស់នៃសមាជិកភាព និងការចូលរួមនៅក្នុងសមាគមផ្សេងៗ គឺជាសូចនាករមួយសំខាន់បំផុតដែលបង្ហាញពីទំហំមូលធនសង្គមនៅក្នុងសង្គម ។ នៅតាមភូមិក្នុងឃុំសានគរ និងឃុំដីរស្លាប់ ការចូលរួមរបស់គ្រួសារ និងអត្រាសមាជិកភាពនៅតាមក្រុមនានាក្នុងសហគមន៍ បានកើនខ្លាំងណាស់ ចាប់ពីឆ្នាំ២០០០ ដល់ ២០០៥ ។ យោងតាមលោក Putnam កំណើននេះបង្ហាញពីមូលធនសង្គមដ៏ច្រើន និងការរួបរួមគ្នាល្អនៅក្នុងភូមិ ។ បើមិនដូច្នោះទេ អ្នករិះគន់វិធីសាស្ត្ររបស់លោក Putnam គឺជាអ្នកនិយាយត្រូវ ។ ការស៊ើបអង្កេតដ៏ល្អមួយបែបទៀត បំបែរការស្រាវជ្រាវទៅផ្តោតលើលទ្ធភាពបានប្រើប្រាស់ស្តុកនៃមូលធនសង្គម នៅក្នុងស្ថានភាពជាក់ស្តែងនៃសង្គមនីមួយៗ ។ សំរាប់ឃុំសានគរ និងឃុំដីរស្លាប់ គេមើលឃើញច្បាស់ថា គ្រួសារនានាមានលទ្ធភាពប្រើប្រាស់មូលធនសង្គមជាចំណងផ្សារភ្ជាប់ និងមូលធនសង្គមជាស្ពានចំលងក៏ពិតមែន ប៉ុន្តែពួកគាត់សឹងតែត្រូវផាត់ចេញទាំងស្រុងពីមូលធនសង្គមជាចំណងទាក់ទង ។ ជាទូទៅ គ្រួសារអ្នកឆ្លើយសំភាសន៍ តែងខ្វះចំណងទាក់ទងតាមខ្សែបញ្ឈរជាមួយនឹងបុគ្គល/ស្ថាប័នមានអំណាច ដែលអាចអនុញ្ញាត អោយពួកគាត់អាចប្រើប្រាស់ធនធានបានយ៉ាងសក្តិសិទ្ធិដើម្បីទាញយកផលប្រយោជន៍ក្នុងរយៈពេលវែង ។

សរុបមក បញ្ហាចំបងគេដែលគ្រួសារនានានៅឃុំសានគរ និងឃុំដីរស្លាប់ត្រូវប្រឈមមុខ គឺការពង្រឹង និងពង្រីកបណ្តាញមូលធនសង្គមដែលជាចំណងផ្សារភ្ជាប់ និងជាស្ពានចំលងរបស់ខ្លួន អោយវាតភ្ជាប់ទៅនឹងបណ្តាញមូលធនសង្គមជាចំណងទាក់ទងនានា មានទាំងចំណងទាក់ទងជាមួយស្ថាប័នរដ្ឋផង ។ ដូចគ្នាដែរ បញ្ហាប្រឈមរបស់អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត គឺក្រៅពីការកសាងសមត្ថភាពរបស់សហគមន៍ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ គេត្រូវជួយសំរួលអោយអ្នកភូមិមានលទ្ធភាពប្រើប្រាស់ស្តុកមូលធនសង្គមជាចំណងទាក់ទង ដើម្បីអោយពួកគាត់អាចប្រើប្រាស់បាននូវធនធានដែលបច្ចុប្បន្នគេផាត់គាត់ចេញ និងអោយពួកគាត់មានសំលេងនៅក្នុងសេចក្តីសំរេចផ្សេងៗ ដែលអាចប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគាត់ ។

## កំណត់សំគាល់

១. វិធីសាស្ត្រស្រដៀងគ្នា ត្រូវបានដាក់ចូលយ៉ាងស៊ីជម្រៅនៅក្នុង FitzGerald and So 2007 ។

២. ទិន្នន័យ និងតារាង ដូចមានបង្ហាញនៅតាមផ្នែកដូចតទៅ បានមកពីការសិក្សារបស់ CCC ស្តីពីការស្វែងយល់ពីតួនាទីមូលធនសង្គម នៅពេលមានទឹកជំនន់ និងគ្រោះរាំងស្ងួតៈ ការសិក្សានៅ ៥ភូមិ ក្នុង ២តំបន់អេកូឡូស៊ីនៅខេត្តកំពង់ធំ (ក្រុមវិភាគបញ្ហាអភិវឌ្ឍន៍ និងអ្នកចូលរួមស្រាវជ្រាវ ខែសីហា ២០០៧) ។

## ឯកសារយោង

*សូមមើលឯកសារយោងក្នុងអត្ថបទភាសាអង់គ្លេស*